## ៥_ ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៦២២ អយក.ប្រក**

**ស្ដីពីការប្ដូរឈ្មោះ សាលាបឋមសិក្សា «ហ៊ុន សែន_អ្នកលឿង»**

* * *

រដ្ឋមន្ត្រីអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្ដេច ព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១_១១_១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០_៧_១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០_១១_១៩៨៦ ស្ដីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានពិនិត្យលិខិតស្នើសុំរបស់ការិយាល័យអប់រំ យុវជននិងកីឡា ស្រុកពាមរក៍ លេខ ៤៦_៩៦ អយក.ពរ ចុះថ្ងៃទី ២៩_៣_១៩៩៦ ដោយមានចំណារឯកភាពរបស់អភិបាលខេត្តរង ទី ២ ចុះថ្ងៃទី ០៨_៥_១៩៩៦
- តាមយោបល់ឯកភាពរបស់នាយកដ្ឋាន ចំនេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង ប្ដូរឈ្មោះសាលាបឋមសិក្សាអ្នកលឿង នៅស្រុកពាមរក៍ ខេត្តព្រៃវែង មកជាសាលាបឋមសិក្សា «**ហ៊ុន សែន**» **អ្នកលឿង**» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៥_១៩៩៦ នេះតទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកពាមរក៍ នាយកដ្ឋានសាលាបឋមសិក្សា «ហ៊ុន សែន_អ្នកលឿង» មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**តូល ឡោះ**

* * *

## ៦_ ទីស្តីការក្រសួងធម្មការ និងសាសនា

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១២០ កធស ស្តីពីការតែងតាំង**

**គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា**

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១_១១_៩៣
- បានឃើញព្រះរាជក្រមលេខ នស.រកម ១០៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- យោងតាមការចាំបាច់របស់ក្រសួងធម្មការ និង សាសនា

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សាមួយ ដែលមានសមាសភាពដូចតទៅ :

១- ឯកឧត្តម **ហឿន វណ្ណរ័ត្ន** រដ្ឋលេខាធិការ ប្រធាន

២- ឯកឧត្តម **ដោក ណារិន** អនុរដ្ឋលេខាធិការទទួលបន្ទុកអគ្គាធិការ